ព្រឹទ្ធសភា

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍
# ស្តីពី
# លទ្ធផលការងាររបស់ព្រឹទ្ធសភា
# ប្រចាំខែតុលា ឆ្នាំ២០១៧

នៅក្នុងខែតុលា ឆ្នាំ២០១៧នេះ ព្រឹទ្ធសភាបានបំពេញមុខងាររបស់ខ្លួនដូចតទៅ:

## ១.សកម្មភាពថ្នាក់ដឹកនាំព្រឹទ្ធសភា

### ១.១ សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រធានព្រឹទ្ធសភា បាន៖

-ទទួលភារកិច្ចជាប្រមុខរដ្ឋស្តីទីចំនួន០១លើក

-អញ្ជើញដឹកនាំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភាចំនួន០២លើក និងសម័យប្រជុំពេញអង្គព្រឹទ្ធសភាចំនួន០២លើក

-អញ្ជើញទទួលព្រះរាជដំណើរយាងមាតុភូមិនិវត្តន៍របស់ **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា និង **សម្តេចព្រះមហាក្សត្រី មុនិនាថ សីហនុ** ពីទីក្រុងប៉េកាំង នៃសាធារណរដ្ឋប្រជាមានិតចិន

-អនុញ្ញាតឲ្យលោកជំទាវ Eva NGUYEN BINH ឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាព នៃសាធារណរដ្ឋបារាំង ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ចូលជួបសម្តែងការគួរសម និងសវនាការ

-អនុញ្ញាតឲ្យប្រតិភូយុវជន នៃសមាគមនាវាយុវជនអាស៊ីអាគ្នេយ៍កម្ពុជា ចំនួន២៩នាក់ ចូលជួបសម្តែងការគួរសម និងផ្តល់អនុសាសន៍មុនពេលទៅចូលរួមក្នុងកម្មវិធីនាវាយុវជនអាស៊ីអាគ្នេយ៍ និងជប៉ុនលើកទី៤៤ (44th SSEAYP) ឆ្នាំ២០១៧

-អនុញ្ញាតជូនគណៈប្រតិភូគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា ចំនួន២២រូប ចូលជួបសម្តែងការគួរសម

-អញ្ជើញគោរពវិញ្ញាណក្ខន្ធ និងផ្តល់ភ្លើងបូជាសព ឯកឧត្តម **អ៊ុំ ម៉ាន្ធរីន** សមាជិកព្រឹទ្ធសភា

-អញ្ជើញជាអធិបតី និងផ្តល់ភ្លើងបូជាសពឧបាសិកា **ធួន អាំ** ដែលត្រូវជាម្តាយមីងបង្កើតរបស់សម្តេច ស្ថិតនៅភូមិ៣ ឃុំកោះសូទិន ស្រុកកោះសូទិន ខេត្តកំពង់ចាម

-អញ្ជើញចុះសួរសុខទុក្ខប្រជាពលរដ្ឋចាស់ជរាចំនួន០៥គ្រួសារ នៅភូមិឬស្សីទី១ សង្កាត់ស្ទឹងមានជ័យទី១ ខណ្ឌមានជ័យ និងអាជ្ញាធរសង្កាត់ព្រែកថ្មី ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ ព្រមទាំងប្រជាពលរដ្ឋចាស់ជរា ស្ថិតនៅភូមិ៣ ឃុំកោះសូទិន ស្រុកកោះសូទិន ខេត្តកំពង់ចាម

-ពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន១០ច្បាប់ និងជ្រាបជាព័ត៌មានចំនួន៧១ច្បាប់ ។

**១.២.ឯកឧត្តម ង៉ែ ប៉េណា អនុប្រធានទី១ព្រឹទ្ធសភា បាន :**

-ទទួលភារកិច្ចជាប្រធានស្តីទីព្រឹទ្ធសភាចំនួន០១លើក

-អញ្ជើញចូលរួមកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភាចំនួន០៣លើក និងសម័យប្រជុំពេញអង្គព្រឹទ្ធសភាចំនួន០២លើក

-អញ្ជើញចុះជួបសំណេះសំណាល និងពិភាក្សាការងារជាមួយនឹងក្រុមប្រឹក្សាឃុំ សង្កាត់ និងស្មៀនមកពីខេត្តកំពត និងខេត្តកែប ដោយមានការអញ្ជើញចូលរួមពីប្រធានក្រុមប្រឹក្សាខេត្ត អភិបាលខេត្ត និងថ្នាក់ដឹកនាំជុំវិញខេត្ត សរុបចំនួន៥២១នាក់ នៅសាលប្រជុំសាលាខេត្តកំពតចាស់

-អញ្ជើញចូលរួមគោរពវិញ្ញាណក្ខន្ធ ពិធីបូជាសព និងពិធីបុណ្យគម្រប់ខួប ៧ថ្ងៃ សពឯកឧត្តម **អ៊ុំ ម៉ាន្ទីរីន** សមាជិកព្រឹទ្ធសភា ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុតរបស់ **ព្រះករុណាព្រះបាទ សម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា និង**សម្តេចមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ** នៅទីមេរុ មុខវត្តបទុមវត្តី

-ពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន១៨ច្បាប់ និងជ្រាបជាព័ត៌មានចំនួន៦៥ច្បាប់ ។

**១.៣.ឯកឧត្តម ទេព ងន អនុប្រធានទី២ ព្រឹទ្ធសភា បាន :**

-អញ្ជើញចូលរួមកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភាចំនួន០៣លើក និងសម័យប្រជុំពេញអង្គព្រឹទ្ធសភាចំនួន០២លើក

-អញ្ជើញដឹកនាំគណៈប្រតិភូ ចូលរួមកិច្ចប្រជុំមហាសន្និបាតសហភាពអន្តរសភា (IPU) លើកទី១៣៧ នៅទីក្រុង Saint Petersburg សហភាពសហព័ន្ធរុស្ស៊ី

-អញ្ជើញដឹកនាំប្រជុំត្រៀមសម្រាប់កិច្ចប្រជុំការងារ (IPU) ដើម្បីត្រួតពិនិត្យមើលឡើងវិញលើការត្រៀមឯកសារ រៀបចំខ្លឹមសារឯកសារ និងការងារផ្សេងៗតាមមុខសញ្ញាជាសមត្ថកិច្ចរបស់សមាជិកគណៈប្រតិភូនីមួយៗ

-អញ្ជើញជួបសំណេះសំណាល និងពិភាក្សាការងារជាមួយឯកឧត្តម Evgeni Bushmin អនុប្រធានក្រុមប្រឹក្សាសហព័ន្ធ នៃសភាសហព័ន្ធក្នុងកិច្ចពង្រឹងចំណងមិត្តភាពរវាងប្រទេសទាំងពីរឲ្យកាន់តែល្អថែមទៀត នៅវិមាន Tavrichesky ទីក្រុង Saint Petersburg សហព័ន្ធរុស្ស៊ី

-អញ្ជើញជួបសំណេះសំណាលជាមួយនិស្សិតកម្ពុជាចំនួន១២៨នាក់ ដែលកំពុងសិក្សា នៅទីក្រុង Saint Petersburg សហព័ន្ធរុស្ស៊ី

-អញ្ជើញចូលរួមគោរពវិញ្ញាណក្ខន្ធ ពិធីបូជាសព និងឡើងថ្លែងវិយោគកថាក្នុងពិធីបូជាសពឯក**ឧត្តម អ៊ុំ ម៉ាន្នូរីន**

-អញ្ជើញចូលរួមក្នុងពិធីបុណ្យគម្រប់ខួប៧ថ្ងៃសព ឯកឧត្តម **អ៊ុំ ម៉ាន្នូរីន** អតីតសមាជិកព្រឹទ្ធសភា ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុតរបស់ **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា និង **សម្តេចមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ** នៅទីមេរុ មុខវត្តបទុមវត្តី

-ពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន៩៥ច្បាប់ និងជ្រាបជាព័ត៌មានចំនួន២៦ច្បាប់ ។

**២.សម័យប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ចំនួន០៣លើក:**

ពិនិត្យ និងសម្រេចលើសំណើរបស់គណៈកម្មការទី៣ ទី៦ និងទី៩ព្រឹទ្ធសភា សុំដាក់សេចក្តីស្នើច្បាប់ និងសេចក្តីព្រាងច្បាប់ស្តីពី៖

១.វិសោធនកម្មច្បាប់ស្តីពី ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ

២.វិសោធនកម្មច្បាប់ស្តីពី ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា

៣.វិសោធនកម្មច្បាប់ស្តីពី ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់

៤.វិសោធនកម្មច្បាប់ស្តីពី ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ

៥.ឧបាស្រ័យពាណិជ្ជកម្ម

៦.ការអនុម័តយល់ព្រមលើពិធីសារធ្វើវិសោធនកម្មកិច្ចព្រមព្រៀងក្របខ័ណ្ឌស្តីពីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចទូលំទូលាយ និងកិច្ចព្រមព្រៀងមួយចំនួនទៀតក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌនេះ រវាងសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍(អាស៊ាន) និងសាធារណរដ្ឋប្រជាមានិតចិន

៧.ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងស្តីពី ការទទួលស្គាល់សុពលភាពនៃប្រកាសនីយបត្រតក្កកម្មអឺរ៉ុប រវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងស្ថាប័នប្រកាសនីយបត្រតក្កកម្មអឺរ៉ុប

៨.វិសោធនកម្មមាត្រា៣៧ មាត្រា៣៨ មាត្រា១០៩ និងមាត្រា១៣៦ នៃច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម ដែលត្រូវប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០១០៣/០០៥ ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០០៣

៩.វិសោធនកម្មមាត្រា៦ មាត្រា៤១ មាត្រា៤២ មាត្រា៤៣ និងមាត្រា៩៥ នៃច្បាប់ស្តីពីជលផលដែលត្រូវប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៦/០១១ ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៦

១០.កំណត់របៀបវារៈ និងកាលបរិច្ឆេទបន្តសម័យប្រជុំលើកទី១១ ព្រឹទ្ធសភា នីតិកាលទី៣ ។

**៣. សម័យប្រជុំពេញអង្គចំនួន០២លើក**

ពិនិត្យ និងឲ្យយោបល់លើសេចក្តីស្នើច្បាប់ និងសេចក្តីព្រាងច្បាប់ស្តីពីៈ

១.វិសោធនកម្មច្បាប់ស្តីពី ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ

២.វិសោធនកម្មច្បាប់ស្តីពី ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា

៣.វិសោធនកម្មច្បាប់ស្តីពី ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់

៤.វិសោធនកម្មច្បាប់ស្តីពី ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ

៥.ឧបាស្រ័យពាណិជ្ជកម្ម

៦.ការអនុម័តយល់ព្រមលើពិធីសារធ្វើវិសោធនកម្មកិច្ចព្រមព្រៀងក្របខ័ណ្ឌស្តីពីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចទូលំទូលាយ និងកិច្ចព្រមព្រៀងមួយចំនួនទៀតក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌនេះ រវាងសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍(អាស៊ាន) និងសាធារណរដ្ឋប្រជាមានិតចិន

៧.ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងស្តីពី ការទទួលស្គាល់សុពលភាពនៃប្រកាសនីយបត្រតក្កកម្មអឺរ៉ុប រវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងស្ថាប័នប្រកាសនីយបត្រតក្កកម្មអឺរ៉ុប

៨.វិសោធនកម្មមាត្រា៣៧ មាត្រា៣៨ មាត្រា១០៩ និងមាត្រា១៣៦ នៃច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម

ដែលត្រូវប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០១០៣/០០៥ ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០០៣

៩.វិសោធនកម្មមាត្រា៦ មាត្រា២១ មាត្រា២២ មាត្រា២៣ និងមាត្រា៩៥ នៃច្បាប់ស្តីពីជលផលដែលត្រូវប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៦/០១១ ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៦ ។

**៤.គណៈកម្មការជំនាញនានារបស់ព្រឹទ្ធសភា :**

ក្នុងខែតុលានេះ សមាជិក សមាជិកាព្រឹទ្ធសភា បានបំពេញការងារយ៉ាងសកម្ម តាមតួនាទី ភារកិច្ច និងសមត្ថកិច្ចរបស់ខ្លួនប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ដូចខាងក្រោម :

**៤.១.មុខងារនីតិកម្ម**

-គណៈកម្មការជំនាញបានប្រជុំផ្ទៃក្នុងគណៈកម្មការ និងប្រជុំអន្តរគណៈកម្មការព្រឹទ្ធសភាជាមួយក្រុមតំណាងរាស្ត្រហត្ថលេខី និងតំណាងរាជរដ្ឋាភិបាល ដើម្បីពិនិត្យពិភាក្សាលើសេចក្តីស្នើច្បាប់ និងសេចក្តីព្រាងច្បាប់ចំនួន០៩ច្បាប់ ។

**៤.២.មុខងារតាមដានការអនុវត្តច្បាប់**

-អញ្ជើញចុះបេសកកម្មដើម្បីឈ្វេងយល់អំពីវឌ្ឍនភាព និងបញ្ហាប្រឈមនានាក្នុងការអនុវត្តគោលនយោបាយអភិវឌ្ឍន៍តំបន់ត្រីកោណ និងប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ជូនប្រជាពលរដ្ឋ នៅខេត្តរតនគិរី និងខេត្តស្ទឹងត្រែង

-អញ្ជើញចុះជួបសំណេះសំណាល និងពិភាក្សាការងារជាមួយអាជ្ញាធរខេត្ត ក្រុង ឃុំ សង្កាត់ ដើម្បីឈ្វេងយល់អំពីការអនុវត្តតួនាទី ភារកិច្ចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិថ្មី នៅខេត្តត្បូងឃ្មុំ

-អញ្ជើញចុះបំពេញបេសកកម្មដើម្បីសិក្សាឈ្វេងយល់អំពីការអនុវត្តច្បាប់ពាក់ព័ន្ធនឹងវិស័យជាសមត្ថកិច្ចរបស់គណៈកម្មការ ដោយផ្តោតលើវិស័យការងារ និងមុខរបរពលករក្រៅប្រព័ន្ធ នៅខេត្តកំពង់ធំ

-អញ្ជើញចូលរួមបើកវេទិកាភូមិភាគជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ស្តីពី ការពង្រឹងសមត្ថភាពក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី៤ នៅខេត្តតាកែវ ខេត្តកំពត និងខេត្តកែប។

**៤.៣.មុខងារតំណាង**

-បានទទួលពាក្យបណ្តឹងចំនួន០៤ករណី ផ្ញើលិខិតអន្តរាគមន៍ទៅស្ថាប័នមានសមត្ថកិច្ចដោះស្រាយចំនួន០៥ករណី កំពុងពិនិត្យសិក្សាចំនួន០៤ករណី និងទទួលពាក្យបណ្តឹងជូនជ្រាបចំនួន១១ករណី

-ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៩ រៀបចំវេទិកាស្តីពី ការពង្រឹងសមត្ថភាពក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៤ នៅខេត្តតាកែវ ខេត្តកំពត និងខេត្តកែប

-ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៨ រៀបចំវេទិកាស្តីពី ការពន្យល់អំពីការបោះឆ្នោត និងការផ្តល់វិភាគទាន នៅខេត្តស្ទឹងត្រែង និងខេត្តរតនគិរី

-អញ្ជើញចូលរួមស្តាប់បទបង្ហាញស្តីពី ការផ្សព្វផ្សាយអំពីវិធានប្រពៃណី និងការរស់នៅ ព្រមទាំងគោលនយោបាយច្បាប់ជាតិ និងច្បាប់អន្តរជាតិនានា ដែលពាក់ព័ន្ធជនជាតិដើមភាគតិច

-អញ្ជើញចូលរួមសិក្ខាសាលាស្តីពី ការបង្កើនការយល់ដឹង និងពិគ្រោះយោបល់កសាងភាពធន់នៃវិស័យស្បៀងកសិកម្ម ចំពោះការប្រែប្រួលអាកាសធាតុនៅតំបន់ភាគខាងត្បូង ដោយសារបាតុភូតអែលនីញ្ញូនៅកម្ពុជា

-អញ្ជើញជួបពិភាក្សាការងារជាមួយលោក Yoshitomo Minamoto នាយកមជ្ឈមណ្ឌលថែទាំមនុស្សចាស់ នៅទីក្រុងហ៊ីរ៉ូស៊ីម៉ា

សមាជិក សមាជិកាព្រឹទ្ធសភា អញ្ជើញចុះតាមបណ្តាខេត្ត ក្រុង រាជធានីទូទាំងប្រទេសចំនួន១២៧លើក ដើម្បីចុះជួបពិភាក្សាការងារ សំណេះសំណាល សាកសួរសុខទុក្ខប្រជាពលរដ្ឋ កងទ័ព សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្តចុះពិនិត្យព្យាបាលជំងឺជូនប្រជាពលរដ្ឋ ពិនិត្យការដ្ឋានសាងសង់ សម្ពោធសមិទ្ធផលនានា តាមដានការអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់ក្រោមជាតិ ការអនុវត្តគោលនយោបាយភូមិ ឃុំមានសុវត្ថិភាព ឈ្វេងយល់អំពីស្ថានភាពសិទ្ធិមនុស្ស ការអនុវត្តច្បាប់ កែលម្អសេវាសាធារណៈ ពង្រឹងអភិបាលកិច្ចល្អនៅមូលដ្ឋាន និងគោលនយោបាយផ្សេងៗលើគ្រប់វិស័យ ព្រមទាំងបានចូលរួមក្នុងពិធីផ្លូវការ និងពិធីផ្សេងៗសរុបចំនួន១៣១លើក ។

**៥. កិច្ចសហប្រតិបត្តិការអន្តរជាតិ** :

-លោកជំទាវ **ទី បូរ៉ាស៊ី** និងឯកឧត្តម **ម៉ាន់ ឈឿន** អញ្ជើញទៅទស្សនកិច្ចសិក្សាស្តីពីការទូតសភា នៅសាធារណរដ្ឋបារាំង និងប្រទេសលុចហ្សំបួរ

-ឯកឧត្តម **ឈិត គឹមយាត** ឯកឧត្តម **យ៉ង់ សែម** និងលោកជំទាវ **ពុំ ស៊ីចាន់** អញ្ជើញចូលរួមមហាសន្និបាតសហភាពអន្តរសភា (IPU) លើកទី១៣៧ នៅទីក្រុង Saint Petersburg សហភាពសហព័ន្ធរុស្ស៊ី

-ឯកឧត្តម **ជា ជេដ្ឋ** ឯកឧត្តម **ឈួន ឡេង** ឯកឧត្តម **ម៉ែន ស៊ីផាន់** និងលោកជំទាវ **ឡាយ បូនី** អញ្ជើញបំពេញទស្សនកិច្ចសិក្សាឈ្វេងយល់អំពី វដ្តនៃការរៀបចំថវិកា ការត្រួតពិនិត្យ និងការវិភាគថវិកា នៅប្រទេសស៊ុយអែត

-ឯកឧត្តម **អ៊ុក ប៊ុនឈឿន** ឯកឧត្តម **ជា សុន** ឯកឧត្តម **ថុង ចន់** ឯកឧត្តម **ហេង បូរ៉ា** និងឯកឧត្តម **ជុំ វង** អញ្ជើញបំពេញបេសកកម្ម ដើម្បីឈ្វេងយល់អំពីបទពិសោធន៍ការងារនីតិកម្ម នៅរដ្ឋសភានីតិប្បញ្ញត្តិជាតិ និងការងារយុត្តិធម៌ នៅក្រសួងយុត្តិធម៌ នៅព្រះរាជាណាចក្រថៃឡង់ដ៍

-ឯកឧត្តម **ទាវ វណ្ណុល** ឯកឧត្តម **អន ស៊ុំ** ឯកឧត្តម **អ៊ុក គង់** និងលោកជំទាវ **កែវ ម៉ាលី** អញ្ជើញទៅទស្សនកិច្ចសិក្សានៅព្រះរាជាណាចក្រជប៉ុន

-ឯកឧត្តម **ប៊ូ ថង** អញ្ជើញជួបសំណេះសំណាលការងារជាមួយឯកឧត្តមឯកអគ្គរដ្ឋទូតឡាវ ប្រចាំនៅព្រះរាជាណាចក្រកម្ពុជាស្តីពី ការផ្លាស់ប្តូរព័ត៌មានថ្មីៗរវាងប្រទេសកម្ពុជា ឡាវ

-ឯកឧត្តម **ទាវ វណ្ណុល** និងឯកឧត្តម **អ៊ុក គង់** អញ្ជើញជួបពិភាក្សាការងារជាមួយលោក **OKAWA** នាយកក្រុមហ៊ុន Dekasia, លោក **NOZAKI** នាយកក្រុមហ៊ុន Timayak store, លោក **NISHINA** នាយកក្រុមហ៊ុន Nishina ដែលជាក្រុមហ៊ុនវេចខ្ចប់ចំណីអាហារ ហើយមានសិក្ខាកាម(ពលករ)កម្ពុជាចូលរួម៥២នាក់ ស្ថិតនៅខេត្ត OKAYAMA ប្រទេសជប៉ុន ។៚

រាជធានីភ្នំពេញ, ថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១៧

**ជ.ប្រធានព្រឹទ្ធសភា**

**អនុប្រធានទី២**

**ទេព ងន**

ចម្លងជូន:

- ក្រសួងព្រះបរមរាជវាំង
- ក្រុមប្រឹក្សាធម្មនុញ្ញ
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ក្រសួងយុត្តិធម៌